**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខុទ្ទកាល័យសម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**
**នាយករដ្ឋមន្ត្រី**

**ក្រុមអ្នកនាំពាក្យ**

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## លទ្ធផលជំនួបរវាងសម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម គីម ជីន ព្យូ (Kim Jin Pyo) ប្រធានរដ្ឋសភា នៃសាធារណរដ្ឋកូរ៉េ នៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២៣

នៅវិមានសន្តិភាព នារសៀលថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២៣ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានទទួលជំនួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយ **ឯកឧត្តម គីម ជីន ព្យូ** (Kim Jin Pyo) ប្រធានរដ្ឋសភា នៃសាធារណរដ្ឋកូរ៉េ។

ជាកិច្ចចាប់ផ្តើម **សម្តេចធិបតី** បានសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅចំពោះ **ឯកឧត្តម គីម ជីន ព្យូ** និងគណៈប្រតិភូដែលបានមកបំពេញទស្សនកិច្ចនៅកម្ពុជា និងបានទទួលនូវលទ្ធផលប្រកបដោយផ្លែផ្កា តាមរយៈជំនួបជាមួយថ្នាក់ដឹកនាំ រដ្ឋសភា ព្រឹទ្ធសភា និង **សម្តេចតេជោ** ប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ។ **សម្តេចធិបតី** ក៏បានជម្រាបជូន **ឯកឧត្តម គីម ជីន ព្យូ** ផងដែរអំពីជំនួបទ្វេភាគីដ៏ល្អប្រសើររវាង **សម្តេចធិបតី** និង **ឯកឧត្តមប្រធានាធិបតី យូន ស៊ុកយ៉ុល** នៅរដ្ឋធានីហ្សាការតា សាធារណរដ្ឋឥណ្ឌូណេស៊ី នៅក្នុងអំឡុងកិច្ចប្រជុំកំពូលអាស៊ានលើកទី៤៣ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ។

**ឯកឧត្តម គីម ជីន ព្យូ** បានសម្តែងនូវការអបអរសាទរជូនចំពោះ **សម្តេចធិបតី** ដែលត្រូវបានជ្រើសតាំងជានាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៧ នៃរដ្ឋសភា កាលពីថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ហើយ **ឯកឧត្តម** ជឿជាក់ថា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចធិបតី** កម្ពុជានឹងអាចសម្រេចបាននូវចក្ខុវិស័យឆ្នាំ២០៥០ ក្នុងការក្លាយជាប្រទេសមានចំណូលខ្ពស់។ **ឯកឧត្តម** ក៏បានរំលើកអំពីការរីកចម្រើននៃវិស័យពាណិជ្ជកម្ម និងសេដ្ឋកិច្ច បន្ទាប់ពីការតភ្ជាប់ទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ នៅឆ្នាំ១៩៩៧។

ជាមួយគ្នានេះ រដ្ឋាភិបាល និងរដ្ឋសភានៃសាធារណរដ្ឋកូរ៉េនឹងបន្តកិច្ចសហការជាមួយនឹងសមភាគីកម្ពុជា ក្នុងការជំរុញការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP) និងសង្ឃឹមថាកូរ៉េនិងកម្ពុជានឹងបន្តគាំទ្រគ្នាទៅវិញទៅមកនៅក្នុងក្របខ័ណ្ឌអាស៊ាននិងតំបន់មេគង្គសម្រាប់វិបុលភាព និងការអភិវឌ្ឍនាពេលអនាគត។

ជាការឆ្លើយតប **សម្តេចធិបតី** បានថ្លែងអំណរគុណចំពោះ **ឯកឧត្តម គីម ជីន ព្យូ** ចំពោះការអបអរសាទរ និងបានបញ្ជាក់អំពីស្ថានភាពនៃការបោះឆ្នោតសកលនៅកម្ពុជា ដែលទទួលបានការចូលរួមយ៉ាងកុះករពីប្រជាពលរដ្ឋ។ លទ្ធផលនៃការបោះឆ្នោតនេះ ក៏បង្ហាញអំពីការពេញចិត្ត និងភាពកក់ក្តៅនៃការដឹកនាំរបស់ **សម្តេចតេជោ** និងគណបក្សប្រជាជនកម្ពុជា ក្នុងការដោះស្រាយបញ្ហាជូនប្រជាជន ជាពិសេសក្នុងអំឡុងវិបត្តិជំងឺកូវីដ-១៩ និងការដាក់ចេញគោលនយោបាយគាំពារសង្គមដ៏មានប្រសិទ្ធភាពជាដើម។ ក្នុងស្មារតីនេះ **សម្តេចធិបតី** បានថ្លែងអំណរគុណដល់រដ្ឋាភិបាល និងប្រជាជនកូរ៉េ ដែលតែងគាំទ្រកិច្ចអភិវឌ្ឍរបស់កម្ពុជា និងបានបញ្ជាក់ថា ការរីកចម្រើនរបស់កម្ពុជាសព្វថ្ងៃនេះ គឺមិនអាចកាត់ផ្តាច់ចេញពីការគាំទ្ររបស់រដ្ឋាភិបាល និងប្រជាជនកូរ៉េនោះឡើយ។

**សម្តេចធិបតី** និង **ឯកឧត្តម គីម ជីន ព្យូ** បានបន្តពិភាក្សាអំពីការពង្រឹងកិច្ចសហប្រតិបត្តិការបន្ថែមចំពោះវិស័យយោធា សេដ្ឋកិច្ច និងការផ្សារភ្ជាប់រវាងប្រជាជន និងប្រជាជន។ ជាក់ស្តែង **សម្តេចធិបតី** បានស្នើលើកកម្ពស់កម្រិតនៃទំនាក់ទំនងរវាងកម្ពុជា-កូរ៉េ ឱ្យក្លាយទៅជា **"ភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ"** និងបានស្នើដល់ភាគីកូរ៉េពង្រីកបន្ថែមនូវទំនាក់ទំនងរវាងកងទ័ពនៃប្រទេសទាំងពីរ ដូចជា ដំណើរទស្សនកិច្ចរបស់កងនាវានៃកងទ័ពជើងទឹកកូរ៉េមកកាន់កម្ពុជាជាដើម។ **សម្តេចធិបតី** ក៏បានឯកភាពតាមការលើកឡើងរបស់ **ឯកឧត្តម គីម ជីន ព្យូ** ក្នុងការជំរុញការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ ក៏ដូចជាក្របខ័ណ្ឌពហុភាគីដទៃទៀត ដើម្បីជំរុញពាណិជ្ជកម្មនៃប្រទេសទាំងពីរ និងបានស្នើភាគីកូរ៉េបន្តផ្តល់ការគាំពារ និងពិចារណាបង្កើនកូតាដល់ពលករកម្ពុជានៅប្រទេសកូរ៉េផងដែរ។ ក្រៅពីនេះ ថ្នាក់ដឹកនាំទាំងពីរបានឯកភាពក្នុងការពង្រីកការផ្សារភ្ជាប់រវាងប្រជាជន និងប្រជាជនដោយកម្ពុជាបន្តបង្ហាញជំហរគាំទ្របេក្ខភាពសាធារណរដ្ឋកូរ៉េ ក្នុងការធ្វើជាម្ចាស់ផ្ទះពិព័រណ៍ពិភពលោកនៅទីក្រុងប៊ូសាន ឆ្នាំ២០៣០ និងបានស្នើកូរ៉េបន្តជួយកម្ពុជា ក្នុងវិស័យវារីកម្ម កសិកម្ម និងបច្ចេកវិទ្យាទំនើបៗ ក៏ដូចជាការវិនិយោគលើសេដ្ឋកិច្ចបៃតង និងការបណ្តុះបណ្តាលវិជ្ជាជីវៈ។

ជាចុងបញ្ចប់ **សម្តេចធិបតី** បានជូនពរ ដល់ **ឯកឧត្តម គីម ជីន ព្យូ** និងគណៈប្រតិភូ ឱ្យទទួលបានជោគជ័យក្នុងបេសកកម្ម និងសូមធ្វើដំណើរមាតុភូមិនិវត្តន៍ប្រកបដោយសុខសុវត្ថិភាព៕

ថ្ងៃសុក្រ ៨រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២៣